**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ ៧៦៥ / ២៣ ក. ស. ភ.

ថ្ងៃច័ន្ទ ១៣រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព. ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០២៣

# សេចក្តីជូនដំណឹង

## ស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃ
## ការងារចំនួន ២គម្រោង ស្ថិតនៅចំណតផែកុងតឺន័រLM១៧រួមមាន៖
## ១-សាងសង់ដំបូលជម្រកទូអូស្គ ចំនួន ២គ្រឿង ទំហំ ៤,៧៤ម៉ែត្រx៣០,៦៣ម៉ែត្រ
## ២-សាងសង់របងលួសសំណាញ់ ប្រវែង ៣៥៤ម៉ែត្រ នៅផ្នែកខាងជើងជាប់របងក្រុមហ៊ុន Mekong Sentosa Logistics Co.,Ltd និងសាងសង់របងលួសសំណាញ់ច្រកចេញទី២ ប្រវែង ១៣ម៉ែត្រ

កំពង់ផែស្វយ័តភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា កំពង់ផែស្វយ័តភ្នំពេញនឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការលើការងារចំនួន ២គម្រោងស្ថិតនៅចំណតផែកុងតឺន័រLM១៧រួមមាន៖ ១-សាងសង់ដំបូលជម្រកទូអូស្គ ចំនួន ២គ្រឿង ទំហំ ៤,៧៤ម៉ែត្រx៣០,៦៣ម៉ែត្រ ២-សាងសង់របងលួសសំណាញ់ ប្រវែង ៣៥៤ម៉ែត្រ នៅផ្នែកខាងជើងជាប់របងក្រុមហ៊ុនMekong Sentosa Logistics Co.,Ltd និងសាងសង់របងលួសសំណាញ់ច្រកចេញទី២ ប្រវែង ១៣ម៉ែត្រ។

កំពង់ផែស្វយ័តភ្នំពេញបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ឯកសារដេញថ្លៃមានដាក់លក់ នៅអង្គភាពលទ្ធកម្ម កំពង់ផែស្វយ័តភ្នំពេញដែលមានអាសយដ្ឋានអគារលេខ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពី**ថ្ងៃទី**១៥.....**ខែ**សីហា **ឆ្នាំ២០២៣** តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០១០ ៤៤៤ ៦៤១)។

កាលបរិច្ឆេទឈប់ទទួលពាក្យសំណើដេញថ្លៃនៅម៉ោង១៥:៣០ ថ្ងៃទី១៣..ខែកញ្ញា....ឆ្នាំ២០២៣។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ **វេលាម៉ោង** ១៥:៣០**នាទី ថ្ងៃទី**១៣...**ខែ**..កញ្ញា........**ឆ្នាំ២០២៣។**

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយក**
**និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ហ៊ី ប៊ាវី**

**ចម្លងជូន**
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ